# ស្ថានភាពអតិផរណាកម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០១១

## I. ស្ថានភាពសេដ្ឋកិច្ចសកល និងជំហរគោលនយោបាយរូបិយវត្ថុ

### ក- ស្ថានភាពទូទៅនៃសេដ្ឋកិច្ចសកល

របាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កាលពីខែមករា ឆ្នាំ២០១១ បានបង្ហាញថា នៅឆ្នាំ២០១០ សេដ្ឋកិច្ចសកលលោកកើន ៥% សេដ្ឋកិច្ចប្រទេសជឿនលឿនកើន ៣% និងសេដ្ឋកិច្ចប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍អាចនឹងមានកំណើនរហូតដល់ ៧,១%។ សហរដ្ឋអាមេរិកមានកំណើនដល់ ២,៨% ខណៈដែលកំណើនសេដ្ឋកិច្ចប្រទេសចិនកើន ១០,៣% ឥណ្ឌាកើន ៩,៧% និងអាស៊ាន-៥ កើន ៦,៧% នៅឆ្នាំ២០១០ ។ របាយការណ៍របស់ IMF ក៏បានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចសកលលោក សេដ្ឋ-កិច្ចប្រទេសជឿនលឿន និងសេដ្ឋកិច្ចប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍អាចនឹងធ្លាក់ចុះបន្តិចមកត្រឹម ៤,៤% ២,៥% និង ៦,៥% រៀងគ្នានៅឆ្នាំ២០១១ ខណៈដែលកំណើនសេដ្ឋកិច្ចប្រទេសចិន ឥណ្ឌា និងអាស៊ាន-៥ នឹងថយចុះបន្តិចមកត្រឹម ៩,៦% ៨,៤% និង ៥,៥% រៀងគ្នា ក្នុងអំឡុងពេលដូចគ្នា[1] ។







### ខ- ស្ថានភាពអតិផរណា

អត្រាអតិផរណារបស់ប្រទេសជឿនលឿន កំពុងមាននិន្នាការកើនឡើង ប៉ុន្តែនៅមានកម្រិតទាប នៅឡើយ ដោយអតិផរណារបស់ប្រទេសអាមេរិកបាន និងកំពុងកើនឡើងជាបន្តបន្ទាប់ពី ១,១% នៅខែវិច្ឆិកា ទៅ ១,៥% នៅខែធ្នូ ឆ្នាំ២០១០ និងទៅដល់ ២,១% នៅខែកុម្ភៈ ឆ្នាំ២០១១ ខណៈដែលអតិផរណានៅសហគមន៍អឺរ៉ុបបាននិងកំពុងកើនឡើងជាបន្តបន្ទាប់ពី ១,៩% នៅខែវិច្ឆិកា ឆ្នាំ២០១០ ទៅ ២,២% នៅ ដំណាច់ឆ្នាំ ២០១០ និង ២,៤% នៅខែកុម្ភៈ រៀងគ្នានៅឆ្នាំ ២០១១ ។

ចំណែកអត្រាអតិផរណានៅតំបន់អាស៊ីវិញ ក៏បាននិងកំពុងកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ ។ អតិផរណាប្រទេសចិនបានកើនឡើងជាបន្តបន្ទាប់ពី ៤,៦% នៅដំណាច់ឆ្នាំ២០១០ ទៅ ៤,៩% នៅខែមករា និងកុម្ភៈ ឆ្នាំ២០១១ ។ អតិផរណាប្រទេសសឹង្ហ-បូរីបានកើនឡើងជាបន្តបន្ទាប់ពី ២,៧% នៅខែមិថុនា ទៅ ៣,២% នៅ ខែកក្កដា ទៅ ៣,៧% នៅខែកញ្ញា ទៅ




[1] World Economic Outlook, Jan 2011

៤,៦% នៅដំណាច់ឆ្នាំ២០១០ និងទៅ ៥,៥% នៅមករា ឆ្នាំ២០១១ ។ ឯអតិផរណាប្រទេសវៀតណាម បានកើនឡើងយ៉ាងគំហុកពី ៨,២% នៅខែសីហា ទៅ ១១,៧៥% នៅដំណាច់ ឆ្នាំ២០១០ និងបន្តកើនឡើងរហូតដល់ ១២,៣១% ខែកុម្ភៈ ឆ្នាំ២០១១ ខណៈដែលអតិផរណាថៃមាននិន្នាការថយចុះបន្តិចពី ៣,០៤% នៅដំណាច់ឆ្នាំ ២០១០ មក ២,៩០% នៅខែកុម្ភៈ ឆ្នាំ២០១១ [2]។

កត្តាចម្បងនៃកំណើនអតិផរណានៅអាស៊ីបណ្តាលមកពី (១)- សន្ទុះនៃកំណើនថ្លៃប្រេងអន្តរជាតិដោយសារភាពរឹករវរនៅពិភពអារ៉ាប់ និងកំណើនតម្រូវការប្រេងលើសកលលោកបន្ទាប់ពីសេដ្ឋកិច្ចសកលលោកបានងើបឡើងវិញ (២)- កំណើននៃថ្លៃម្ហូបអាហារ ដឹកជញ្ជូន និងផ្ទះសម្បែង (៣)- ការខូចខាតផលិតផលកសិកម្មនៅចុងឆ្នាំ ២០១០ និង (៤)- កំណើនឥណទានលើសលុបដើម្បីស្តារសេដ្ឋកិច្ច ។ ខណៈដែលអតិផរណាប្រទេសជឿនលឿនបណ្តាលមកពីការអនុវត្តគោលនយោបាយធូរលុងរបស់បណ្តាលប្រទេសទាំងនោះ (quantitative easing)។

### គ- ជំហរគោលនយោបាយរូបិយវត្ថុ

ជាវិធានការឆ្លើយតបការកើនឡើងនៃអតិផរណា ប្រទេសអាស៊ីនិងសមាគមអាស៊ានមួយចំនួនបានអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិតជាបន្តបន្ទាប់ តាមរយៈការបង្កើនអត្រាការប្រាក់គោលនយោបាយរបស់គេ ។ ក្នុងនោះប្រទេសវៀតណាមបានបង្កើនអត្រាការប្រាក់គោលនយោបាយរបស់គេពី ៦% នៅខែកញ្ញាទៅ ៧% នៅខែតុលា ឆ្នាំ២០១០ និងទៅដល់ ១២% នៅខែមិនា ឆ្នាំ២០១១ ខណៈប្រទេសចិនបានបង្កើនអត្រាប្រាក់គោលនយោបាយពី ៥,៣១% នៅខែកញ្ញា ទៅ ៥,៥៦% នៅខែតុលា ទៅ ៥,៨១% នៅដំណាច់ឆ្នាំ២០១០ និងទៅ ៦,០៦% នៅខែកុម្ភៈ ឆ្នាំ២០១១ ។

ផ្ទុយទៅវិញ ក្នុងខណៈដែលអតិផរណានៃប្រទេសជឿនលឿនស្ថិតនៅក្នុងស្ថានភាពអាចគ្រប់បាន កំណើនសេដ្ឋកិច្ចនៅមានកម្រិតទាប ហើយអត្រានិកម្មភាពនៅមានកម្រិតខ្ពស់ ធនាគារកណ្តាលរបស់ប្រទេសទាំងនោះនៅតែបន្តអនុវត្តគោលនយោបាយរូបិយវត្ថុពង្រីក ពោលគឺធនាគារកណ្តាលអាមេរិក និងសហគមន៍អឺរ៉ុបនៅរក្សាអត្រាការប្រាក់គោលនយោបាយត្រឹមកម្រិត ០,២៥% និង ១% រៀងគ្នានៅខែមិនា ឆ្នាំ២០១១ នេះ[3] ។



Figure 4: Base Rates for Advnaced Countries



Figure 5: Policy Rates for Some Asian Countries

2 http://www.tradingeconomics.com/
3 http://www.tradingeconomics.com/, http://www.aric.adb.org/macro-indicators.php,

## II - ស្ថានភាពសេដ្ឋកិច្ចនិងធនាគារកម្ពុជា

ការងើបឡើងវិញនៃសេដ្ឋកិច្ចសកល គួបផ្សំនិងការខិតខំអនុវត្តកំណែទម្រង់គ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋា-ភិបាល រួមនិងកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្នប្រកបដោយភាពទន់ភ្លន់ និងភាពស៊ីសង្វាក់គ្នាជាមួយគោលនយោបាយសារពើពន្ធ បានជួយជំរុញឲ្យសេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនមួយខ្ពស់ និងមានចីរភាព ។

### ក-កំណើនសេដ្ឋកិច្ច

តាមការព្យាករណ៍ដោយប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាលបានបង្ហាញថា កំណើនសេដ្ឋកិច្ចកម្ពុជាបានកើនក្នុងល្បឿនមួយយ៉ាងលឿនគួរឲ្យកត់សម្គាល់ ក្នុងអត្រាកំណើនប្រចាំឆ្នាំពី ០,១% នៅឆ្នាំ២០០៩ ទៅ ៥,៩% នៅឆ្នាំ២០១០ ។ អត្រាកំណើននេះអាចឆ្លុះបញ្ចាំងតាមរយៈកំណើននៃការនាំចេញ ១១,៧% ការនាំចូល ៩,៥% ការវិនិយោគផ្ទាល់បរទេសសុទ្ធ ៥៣% និងភ្ញៀវទេសចរណ៍ ១៦,៤% នៅក្នុងឆ្នាំ២០១០ ធៀបនឹងឆ្នាំ២០០៩ ។ រាជរដ្ឋាភិបាលក៏បានព្យាករណ៍ថាសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រចាំឆ្នាំរហូតដល់ ៧% នៅឆ្នាំ២០១១ ខណៈ ដែលមូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករណ៍ថាកំណើនសេដ្ឋកិច្ចឆ្នាំ២០១១ ស្មើនឹង ៦,៨% នាគ្រាដូចគ្នានេះ ។

### ខ-ស្ថានភាពអត្រាប្តូរប្រាក់



Figure 6: Currencies Againt Cambodian Riel
Index:End-Dec 2009=100

រយៈពេលប៉ុន្មានខែចុងក្រោយប្រាក់រៀលបានឡើងថ្លៃធៀបជាមួយប្រាក់ដុល្លារអាមេរិក ជាពិសេសនាពេលបួនខែចុងក្រោយនេះ ជាក់ស្តែង អត្រាទិញទីផ្សាររវាងប្រាក់រៀលនឹងប្រាក់ដុល្លារ ប្រាក់រៀលបានឡើងថ្លៃប្រមាណ ០,៤% និងជិត ៤% នាខែកុម្ភៈ ឆ្នាំ ២០១១ ធៀបនឹងខែធ្នូ និងខែដូចគ្នាឆ្នាំ២០១០ ។ ការឡើងថ្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនេះគឺបណ្តាលមកពីតម្រូវការប្រាក់រៀលក្នុងការទិញកសិផលនិងការបង់ពន្ធជូនរដ្ឋកាន់តែមានការកើនឡើង គួបផ្សំនឹងវិធានការផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជាក្នុងការពង្រឹងស្ថិរភាពអត្រាប្តូរប្រាក់ផងដែរ។

ដោយធៀបជាមួយនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មមួយចំនួនប្រាក់រៀលបានចុះថ្លៃ ៧,៦% ៦,៦% ៥,៥% ៤,៨% និង ០,២% ធៀបនឹងប្រាក់រីងហ្គីត ប្រាក់ដុល្លារសឹង្ហបូរី ប្រាក់យ៉េនជប៉ុន ប្រាក់បាតថៃ និងប្រាក់យ៉ន់ចិន និងបានឡើងថ្លៃ ១៣% ធៀបនឹងប្រាក់ដុងវៀតណាម នៅខែកុម្ភៈ ឆ្នាំ២០១១ ធៀបនឹងខែដូចគ្នាឆ្នាំ២០១០ ។

### គ- ចលនាអត្រាការប្រាក់



Figure 7: Loans and Deposits Rates
(13months)

ផ្អែកតាមអត្រាការប្រាក់ថ្លឹងរយៈពេល៦ខែ ធនាគារបានកាត់បន្ថយអត្រាការប្រាក់លើប្រាក់បញ្ញើជាដុល្លារជាបន្តបន្ទាប់ពី ៤,៣% នៅដំណាច់ឆ្នាំ២០០៩មក ៣,៥% នៅខែមករា ឆ្នាំ២០១១ ។ ស្របពេលជាមួយគ្នានោះដែរ ធនាគារក៏បានកាត់បន្ថយអត្រាការប្រាក់លើប្រាក់កំចីជាប្រាក់ដុល្លារ

រហូតដល់ ១៦,៨% នៅក្នុងខែមករានេះបន្ទាប់ពីបានកំឡើងដល់ ១៨,៩% និង ១៩,១% នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ ២០១០ ។

## III- ស្ថានភាពរូបិយវត្ថុ

១- អត្រាកំណើនរូបិយវត្ថុទូទៅ (M2) ឆ្នាំលើឆ្នាំនាខែមករា ឆ្នាំ២០១១ មានកំណើនស្មើនឹង ២០% ដូចកំណើននាខែធ្នូ ឆ្នាំ២០១០ កន្លងទៅដែរ ។ រូបិយវត្ថុទូទៅនេះធ្លាប់មានកំណើនដល់ទៅ ៣៦% ខែមករា ឆ្នាំ ២០១០ និងមានកំណើនត្រឹមតែ ២% ប៉ុណ្ណោះនៅរយៈពេលដូចគ្នា ក្នុងឆ្នាំ២០០៩ ។ ប្រភពចម្បងនៃកំណើនក្នុងខែមករា ឆ្នាំ២០១១ នេះ គឺប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែលមានកំណើន ២៤% ហើយបានរួមចំណែក ១៩% ទៅក្នុងកំណើនរូបិយវត្ថុទូទៅ ២០% នោះ ។

២- ក្នុងខែមករា ឆ្នាំ២០១១ នេះ ទ្រព្យសកម្មបរទេសសុទ្ធមានអត្រាកំណើនឆ្នាំលើឆ្នាំស្មើនឹង ១៥% ដែលប្រហាក់ប្រហែលនឹងកំណើន ១៤% នៅខែធ្នូ ឆ្នាំ២០១០ កន្លងទៅ ។ ទ្រព្យសកម្មបរទេសសុទ្ធធ្លាប់មានកំណើនដល់ទៅ ៣៨% នាគ្រាដូចគ្នា ឆ្នាំ២០១០ និងបានធ្លាក់ចុះដល់កំរិតអវិជ្ជមាន -៤% នៅគ្រាដូចគ្នា ឆ្នាំ២០០៩ ។ ប្រភពចម្បងនៃកំណើនក្នុងខែនេះគឺបណ្តាលមកពី កំណើនទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ដែលរួមចំណែក ៨% នៃកំណើនរូបិយវត្ថុទូទៅ (M2) និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថាន ធនាគារ ដែលរួមចំណែក ៥% នៃកំណើនរូបិយវត្ថុទូទៅ (M2) ។ គិតតាមអត្រាកំណើនប្រចាំខែ ទ្រព្យសកម្ម បរទេសសុទ្ធមានអត្រាកំណើនស្មើនឹង ១,៦% ធៀបនឹងអត្រាកំណើន ០,២% នារយៈពេលដូចគ្នា ឆ្នាំ២០១០ និង ២,៨% នារយៈពេលដូចគ្នា ឆ្នាំ២០០៩ ។







៣- ប្រាក់បញ្ញើអតិថិជនក្នុងប្រព័ន្ធធនាគារ នៅខែមករា ឆ្នាំ២០១១ នេះ មានអត្រាកំណើនឆ្នាំលើឆ្នាំស្មើនឹង ២៤% ស្មើនឹងកំណើននាខែកន្លងទៅ ។ អត្រាកំណើននេះធ្លាប់មានដល់ទៅ ៣៨% នៅគ្រាដូចគ្នា ឆ្នាំ២០១០ និងស្ទើរតែគ្មានកំណើន (0,1%) នៅគ្រាដូចគ្នាឆ្នាំ២០០៩ ។ បើគិតតាមអត្រាកំណើនប្រចាំខែវិញ ប្រាក់បញ្ញើសរុបរយៈពេលមួយខែដើមឆ្នាំ២០១០ ស្មើនឹង ១,៤% ធៀបនឹងកំណើន ១,៥% និង ១,៦% នៅរយៈពេលដូចគ្នា ឆ្នាំ ២០១០ និង ឆ្នាំ២០០៩ រៀងគ្នា ។

៤- អត្រាកំណើនឆ្នាំលើឆ្នាំនៃឥណទានចំពោះវិស័យឯកជនកើនដល់ ២៧% គឺបានបន្តកើនឡើងជាបន្តបន្ទាប់ចាប់ពីដើមឆ្នាំ រហូតមកដល់ចុងឆ្នាំ ២០១០ ប៉ុន្តែកំណើននេះបានធ្លាក់ចុះបន្តិចមកវិញត្រឹម ២៤% នៅខែមករា ឆ្នាំ ២០១១នេះ ។ ឥណទានចំពោះវិស័យឯកជន ធ្លាប់មានកំណើនត្រឹមតែ ៩% ប៉ុណ្ណោះ នៅគ្រាដូចគ្នា ឆ្នាំ ២០១០

និងកើនដល់ទៅ ៤២% នាគ្រាដូចគ្នា ឆ្នាំ ២០០៩ ។ បើគិតតាមអត្រាកំណើនប្រចាំខែវិញ ក្នុងខែមករា ឆ្នាំ២០១១ នេះ ឥណទានចំពោះវិស័យឯកជនមានកំណើនស្មើនឹង ១,៤% ដែលកំណើននេះ ធ្លាប់មានដល់ទៅ ៣,២ % នាគ្រាដូចគ្នាឆ្នាំ ២០១០ និងមានត្រឹមតែ០,៥% ប៉ុណ្ណោះនាគ្រាដូចគ្នាឆ្នាំ ២០០៩ ។

## IV. ស្ថានភាពអតិផរណារបស់កម្ពុជានាខែកុម្ភៈ ឆ្នាំ២០១១

### ក- អតិផរណាខែលើខែ

អតិផរណាខែលើខែ ក្នុងខែកុម្ភៈនេះ បានកើនឡើងដល់ ០,៧% ។ នេះគឺជាការកើនឡើង ៣ខែបន្តបន្ទាប់គ្នា បន្ទាប់ពីបានធ្លាក់ចុះដល់កម្រិតទាបបំផុតប្រចាំឆ្នាំនាខែ វិច្ឆិកា ឆ្នាំ២០១០ ដែលមានអត្រាស្មើ -១% រួចមក ។ សូមកត់សម្គាល់ថា អត្រាអតិផរណាប្រចាំខែក្នុងអំឡុងដើមឆ្នាំនេះ មាននិន្នាការកើនឡើងដូចឆ្នាំ ២០១០ ដែរ ប៉ុន្តែក្នុងល្បឿនលឿនជាងឆ្នាំមុន ។ ជាក់ស្តែង អត្រាអតិផរណាប្រចាំខែ ឆ្នាំ២០១០ នាខែ មករា មានអត្រា ០,០% និងខែកុម្ភៈ មានអត្រា ០,២% ។ ចំណែកឯ ខែមករា និង ខែកុម្ភៈ ឆ្នាំ២០១១ មានអត្រា ០,២% និង ០,៧% រៀងគ្នា ។ ដែលជាអត្រា កំណើនខ្ពស់ជាងឆ្នាំមុន ។ ទាំងនេះជាការឆ្លុះបញ្ចាំងនូវកំណើននៃតម្រូវការរបស់អ្នកប្រើប្រាស់ក្នុងស្រុក តាមរយៈការរីកចម្រើននៃសេដ្ឋកិច្ច និងការកើនឡើង នៃថ្លៃទំនិញនៅទីផ្សារអន្តរជាតិ ដែលមានឥទ្ធិពលមកលើថ្លៃទំនិញក្នុងស្រុក ដូចជាថ្លៃប្រេងឥន្ធនៈដែលជាទំនិញនាំចូលសុទ្ធសាធរបស់ប្រទេសកម្ពុជាជាដើម ។



Figure 10: CPI-(MOM % CHANGE)

គិតតាមបម្រែបម្រួលខែលើខែ នាខែកុម្ភៈ ឆ្នាំ ២០១១ នេះ ក្នុងចំណោមថ្លៃទំនិញទាំង១២ ក្រុម មាន៧ ក្រុមបានកើនឡើង ៤ ក្រុមបានថយចុះ និង ១ ក្រុមមិនមានការប្រែប្រួល ។ ក្រុមទំនិញដែលបាន ឡើងថ្លៃមាន ក្រុមភោជនីយដ្ឋាន ១,៤% ក្រុមទំនិញនិងសេវាផ្សេងៗ ១,២% ក្រុមដឹកជញ្ជូន ០,៩% ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត ០,៨% ក្រុមម្ហូប អាហារ និងភេសជ្ជៈមិនមានជាតិស្រវឹង ០,៦% ក្រុម សុខាភិបាល ០,៣% ក្រុមភេសជ្ជៈមាន ជាតិស្រវឹងនិងថ្នាំជក់ ០,២% ។ ចំណែកឯក្រុមទំនិញ ដែលចុះថ្លៃរួមមាន ក្រុមសម្លៀកបំពាក់ និងស្បែកជើង ០,៧% ក្រុមការកម្សាន្ត និងវប្បធម៌ ០,៤% ក្រុមគមនាគមន៍ ០,៤% និងក្រុមគ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងការថែទាំផ្ទះជាប្រចាំ ០,៧% ខណៈដែលក្រុមការសិក្សាមិនមានការប្រែប្រួល ។



Figure 11: CPI-Subgroups (MOM % CHANGE)

### ខ-អតិផរណាឆ្នាំលើឆ្នាំ

ពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំ ក្រាហ្វខាងក្រោម-ឆ្វេងបានបង្ហាញថា អត្រាអតិផរណាឆ្នាំលើឆ្នាំមាននិន្នាការកើនឡើងក្នុងកម្រិតដែលអាចគ្រប់គ្រងបាននាអំឡុង ២ ខែចុងក្រោយនេះ ទោះបីជាបម្រែបម្រួលខែលើខែមានការប្រែប្រួលខ្លាំងក៏ដោយ ។ ជាក់ស្តែងអត្រាអតិផរណាឆ្នាំលើឆ្នាំមានកម្រិត ៣,៣% និង ៣,៨% នាខែ មករា និង ខែកុម្ភៈ ឆ្នាំ២០១១ រៀងគ្នា ។ ដោយឡែក បើពិនិត្យមើលអតិផរណាប្រចាំឆ្នាំក្នុងខែ កុម្ភៈដូចគ្នា នារយៈកាល ៣ឆ្នាំចុងក្រោយវិញ (ដូចបង្ហាញក្នុងក្រាហ្វខាងក្រោម-ស្តាំ) ស្ថានភាពអតិផរណានៅក្នុង ឆ្នាំ ២០១១ នេះ មានកម្រិតទាបជាងគេ ពោលគឺមានកម្រិតត្រឹម ៣,៨% ធៀបនឹងអត្រា ៧,៣% និង ៦,២% នៃខែកុម្ភៈ ឆ្នាំ២០១០ និង ២០០៩ រៀងគ្នា ។







កត្តាមួយចំនួនដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆ្នាំ នាខែកុម្ភៈ ឆ្នាំ២០១១ ដែលស្មើនឹង ៣,៨% គឺក្រុមម្ហូបអាហារ និងភេសជ្ជៈពុំមានជាតិស្រវឹង ១,៧% *(ត្រូវនឹងសមាមាត្រ ៤៦,១% នៃអត្រាអតិផរណាប្រចាំឆ្នាំ)* ក្រុមដឹកជញ្ជូន ០,៧% *(ត្រូវនឹងសមាមាត្រ ១៧,៩%)* ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ន និងឥន្ធនៈដទៃទៀត ០,៦% *(ត្រូវនឹងសមាមាត្រ ១៤,៩%)* ក្រុមភោជនីយដ្ឋាន ០,៤% *(ត្រូវនឹងសមាមាត្រ ១០,៨%)* និងក្រុមសុខាភិបាល ០,១% *(ត្រូវនឹងសមាមាត្រ ១,៤%)* ។ ដោយឡែកមុខទំនិញ៧ក្រុមទៀតដែលនៅសល់បានចូលរួមចំណែក ០,២% ប៉ុណ្ណោះ *( ត្រូវនឹងសមាមាត្រ ៥,៩% នៃអត្រាអតិផរណាប្រចាំឆ្នាំ)* ។

| Contribution (YOY%) | Dec-10 | Jan-11 | Feb-11 |
|---|---|---|---|
| All Items | 3.1 | 3.3 | 3.8 |
| Food & N A B | 1.6 | 1.6 | 1.7 |
| Transportation | 0.4 | 0.6 | 0.7 |
| Housing W E. | 0.5 | 0.5 | 0.6 |
| Restaurants | 0.1 | 0.2 | 0.4 |
| Health | 0.0 | 0.1 | 0.1 |




នៅខែកុម្ភៈ ខណៈដែលអតិផរណារួមមានអត្រា ៣,៨% អតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃទំនិញក្រុមម្ហូបអាហារមានអត្រា ៣,៧% ។ រីឯអតិផរណាឆ្នាំលើ

ឆ្នាំមិនគិតថ្លៃទំនិញ និងសេវាពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈ ដែលបញ្ចូលទាំងថ្លៃសេវា ក្រុមដឹកជញ្ជូន ផងនោះ មានអត្រា ៣% គឺទាបជាងអតិផរណារួមផងដែរ ។ ទិន្នន័យនេះបង្ហាញថា ថ្លៃម្ហូបអាហារនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ ជាកត្តាចម្បងជំរុញឲ្យអតិផរណារួមកាន់តែមានកម្រិតខ្ពស់ឡើង នៅខែកុម្ភៈនេះ ។ ម្យ៉ាងទៀតអត្រាអតិផរណាមិនរាប់បញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈរួមគ្នាមានអត្រាត្រឹម ១,៨% ដែលជាការ បង្ហាញថាទំនិញជាទូទៅផ្សេងៗទៀតក្រៅពី ២ក្រុមខាង លើ មានការឡើងថ្លៃទាបជាង ប៉ុន្តែក៏ជាអត្រាខ្ពស់ជាង ខែមករា ឆ្នាំ ២០១១ និងខែធ្នូឆ្នាំ ២០១០ ដែលមាន កម្រិតត្រឹម ១,១% និង ០,៦% រៀងគ្នា ។ ទាំងនេះអាចផ្តល់ជាការសន្និដ្ឋានថា តម្រូវការក្នុងស្រុករបស់អ្នក ប្រើប្រាស់មានការកើនឡើង ។

### គ. កត្តាដែលមានឥទ្ធិពលលើអតិផរណា

#### *១- កត្តាថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ*




ក្នុងការគណនាអតិផរណា ម្ហូបអាហារមានមេគុណខ្ពស់ជាងគេគឺ ៤៥% ខណៈប្រេងឥន្ធនៈមានមេគុណ ១៦% នៅក្នុងកន្ត្រកទំនិញនិងសេវា ។ ការប្រែប្រួលថ្លៃប្រេងឥន្ធនៈអាចមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើថ្លៃទំនិញផ្សេងៗទៀតដូចជា ថ្លៃភ្លើងរាស់ ដាំដុះ និងដឹកជញ្ជូន។ល។ ដែលជាសមាសធាតុផ្សំក្នុងការ ធ្វើឲ្យប្រែប្រួលថ្លៃម្ហូបអាហារ និងអតិផរណារួមទៀត ផង ។

ក្នុងខណៈដែលសេដ្ឋកិច្ចពិភពលោកកំពុងងើបឡើងវិញ តម្រូវការប្រេងឥន្ធនៈរបស់សហរដ្ឋអាមេរិក និងចិន ព្រមទាំងបញ្ហាអស្ថិរភាពផ្នែកនយោបាយនៃប្រទេសនាំចេញប្រេងធំៗមួយចំនួន ដូចជា នីស្សេរីយ៉ា លីប៊ី និងអារ៉ាប៊ីសាវឌីត និងការធ្លាក់ថ្លៃប្រាក់ដុល្លារអាមេរិក បានធ្វើឲ្យថ្លៃប្រេង និងម្ហូបអាហារពិភពលោកកើនឡើង ជាបន្តបន្ទាប់ គិតមកដល់ខែកុម្ភៈ ឆ្នាំ២០១១ នេះ ។ ការណ៍នេះ បានធ្វើឲ្យថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារក្នុង ស្រុកមានកំណើនឆ្នាំលើឆ្នាំប្រមាណ ១៩% និង ៣,៩% ក្នុងខែកុម្ភៈ ឆ្នាំ២០១១ នេះ ធៀបនឹង ៣២,៧% និង ៨,៦% នាខែដូចគ្នា ឆ្នាំ២០១០ រៀងគ្នាផងដែរ។

#### *២- កត្តាអតិផរណានៃប្រទេសជិតខាង និងទំនិញនាំចូល*




សម្ពាធអតិផរណាប្រចាំឆ្នាំនៅប្រទេសថៃបានថយល្បឿនបន្តិច ជាលើកទី២ មកកម្រិត ២,៩% ក្នុងខែកុម្ភៈ ឆ្នាំ២០១១ នេះ បន្ទាប់ពីបានបង្កើនល្បឿនរយៈពេល ២ខែ នៅចុងឆ្នាំ២០១០ ខណៈដែល សម្ពាធអតិផរណា នៅប្រទេសវៀតណាម និងចិន មាននិន្នាការកើនឡើងជាបន្តបន្ទាប់ដល់ក្នុងកម្រិត ១២,៣% និង ៤,៩% រៀងគ្នា ។ ការកើនឡើងនៃ អតិផរណារបស់ប្រទេសវៀតណាម និងចិន បូករួមជា មួយបម្រែប

ម្រួលនៃអត្រាប្តូរប្រាក់របស់ចិន និងវៀត- ណាម បានចូលរួមចំណែកមួយផ្នែកក្នុងកំណើនអតិ- ផរណារបស់កម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០១១នេះផងដែរ ខណៈអតិផរណារបស់ប្រទេសថៃអាចមានឥទ្ធិពលតិចតួចលើអតិផរណាកម្ពុជា ដោយសារឥទ្ធិពលនៃអត្រាប្តូរប្រាក់បានជំរុញឲ្យអតិផរណាថៃមានទិសដៅខុសពីអតិផរណាកម្ពុជា ។ លើសពីនេះទៀត ថ្លៃទំនិញនិងសេវានៃប្រទេសដៃគូពាណិជ្ជកម្មទាំងអស់របស់កម្ពុជា ក៏មានទំនាក់ទំនងវិជ្ជមាននឹងអតិផរណាកម្ពុជាផងដែរ ។